ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

លេខ: ០៥០/២២ អអរ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង ទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ចាម"

ព្រឹកថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ចាម»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ខ្លូត ផន ប្រធានក្រុមប្រឹក្សាខេត្ត**
- **លោក ផ្លោក សុវណ្ណ ចៅសង្កាត់កំពង់ចាម ក្រុងកំពង់ចាម**
- **លោក រស់ វីរ៉េត មេឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តកំពង់ចាម ចែកចេញជា ក្រុង០១ ស្រុក០៩ សង្កាត់០៤ និង១០៥ឃុំ ស្មើនឹង ៩១៦ភូមិ។ មានប្រជាពលរដ្ឋរស់នៅចំនួន១.១១៥.៥៨៥នាក់ ស្រី ៥៧៥.៣៥៨នាក់ ស្មើនឹង២៨៤.៣៨៩គ្រួសារ ដោយសក្តានុពលខេត្តកំពង់ចាម ពឹងផ្អែកលើវិស័យកសិកម្មជាចម្បងចំនួន ៦៤,២០%, ឧស្សាហកម្ម និងសិប្បកម្ម ០,៦៧% និងរបរសេវាកម្ម ៣៥,១៣% និងGDP របស់មនុស្សម្នាក់ៗទទួលបាន ១.៦៧៩ ដុល្លាអាមេរិក ធ្វើឱ្យអត្រាភាពក្រីក្រថយចុះមកត្រឹម ១៣,២% នៅឆ្នាំ២០២១។

## II. វឌ្ឍនភាពការងារសំខាន់ៗ

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានបំពេញមុខងារ និងភារកិច្ចជាប្រចាំ ដោយបានដឹកនាំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញសរុបចំនួន ១៦លើក ដើម្បីពិនិត្យ ពិភាក្សា និងអនុម័ត លើសេចក្តីសម្រេចផ្សេងៗ និងបានចូលរួម និងគាំទ្រសកម្មភាព និងផែនការអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍន៍ខេត្ត ឱ្យកាន់តែរីកចម្រើន។ លើសពីនេះ ក្រុមប្រឹក្សាខេត្ត បានចូលរួមជាមួយគណៈអភិបាលខេត្ត ចុះធ្វើការអប់រំផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងចុះសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ ជួបគ្រោះមហន្តរាយផ្សេងៗ ក៏ដូចជាជនក្រីក្រគ្មានទីពឹង។

### ❖ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម

សមិទ្ធផលសំខាន់ៗ ដែលសង្កាត់កំពង់ចាមសម្រេចបាន រួមមាន៖

- បានសាងសង់ផ្លូវបេតុងចំនួន៣ខ្សែប្រវែង និងកែលម្អចិញ្ចើមផ្លូវ ជួសជុលក្រាលការ៉ូឡាស្តិត នៅភូមិទី១៥ និងបានដាក់លូដោះទឹក ដាក់ភ្លើងបំភ្លឺតាមសួនច្បារ ផ្លូវសាធារណៈ សាងសង់ ប្រាំងទន្លេប្រឆាំងនឹងការបាក់ច្រាំងទន្លេមេគង្គ។
- បានយកចិត្តទុកដាក់ និងសហការ ជាមួយមណ្ឌលសុខភាព សាលាបឋមសិក្សា អនុវិទ្យាល័យ មន្ទីរសុខាភិបាល មន្ទីរផែនការ និងមន្ទីរសង្គមកិច្ច ដើម្បីលើកកម្ពស់វិស័យ អប់រំ សុខភាព និងសុខមាលភាពសង្គម។
- បានចុះកំណត់អត្តសញ្ញាណមានចំនួន ១៤៥គ្រួសារ ក្នុងនោះ ក្រ១មានចំនួន៥៥គ្រួសារ ក្រ២មានចំនួន៩០គ្រួសារ ស្ត្រីជាមេគ្រួសារមានចំនួន៩៧គ្រួសារ។
- បានផ្តល់សេវារដ្ឋបាលដល់ប្រជាពលរដ្ឋចំនួន ៩,៨៩៧សេវា និងបានចុះផ្សព្វផ្សាយអំពីនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅតាមសាលារៀន និងតាមរយៈវេទិកាសាធារណៈ។

### ❖ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាឃុំសម្រេចបានរួមមាន៖

- បានកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុងសរុប២ខ្សែ ជួសជុលផ្លូវក្រាលគ្រួសក្រហម និងសាងសង់របងសាលារៀន ក្រាលការ៉ូ ចាក់សាប ធ្វើបន្ទប់ទឹក បង្គោលភ្លើង និងរបងប៉ុស្តិ៍នៅក្នុងឃុំ។
- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារក្រោមអាយុ ០២ឆ្នាំ បានចុះឈ្មោះអ្នកទទួលផលសរុបចំនួន ៣៣៣នាក់ និងបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ មានចំនួន២៥៧គ្រួសារ។

- បានចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ដូសទី០១ ចំនួន ៩៩៣៣នាក់ ស្រីចំនួន ៥៨២៨នាក់ និង ដូសទី០២ ចំនួន ៩០២១នាក់ ស្រីចំនួន ៤៨០៣ និងដូសទី០៣ ចំនួនចំនួន ១៨៤០នាក់ ស្រីចំនួន ១០០៩នាក់។
- ផ្ទៃដីកសិកម្មមានចំនួន៨០% ក្នុងនោះ ស្រែវស្សា មានចំនួន ៤៩៤.៥ហិកតា, ស្រែប្រាំង មានចំនួន ៦៥០.៨ហិកតា, កៅស៊ូ ចំនួន ៤,៩០១.៨ហិកតា, ស្វាយចន្ទីចំនួន ២,១០០ហិកតា, ទុរេន ចំនួន ៤៨១ហិកតា, ស្វាយកែវរមៀត ចំនួន ៥៤៥ហិកតា, ដំណាំរួមផ្សំ ចំនួន ១៦៥ហិកតា និងព្រៃលិចទឹក និងបឹង ចំនួន ៩៥០ហិកតា។
- បានពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋ ក្នុងគោលបំណងលើកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងប្រកបដោយគណនេយ្យភាព។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- បន្តចុះធ្វើការពិគ្រោះយោបល់ជាសាធារណៈ ជាមួយប្រជាពលរដ្ឋសំដៅឈ្វេងយល់ពីបញ្ហាសំណូមពរ និងតម្រូវការនានា នៅមូលដ្ឋាន ដើម្បីរៀបចំផែនការឆ្លើយតប។
- បន្តចាត់វិធានការអប់រំផ្សព្វផ្សាយបទបញ្ជារបស់រាជរដ្ឋាភិបាល និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋ ក្នុងការទប់ស្កាត់ជំងឺឆ្លងនានា ពិសេសជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពខ្ពស់។
- បន្តគាំទ្រយន្តការការិយាល័យប្រជាពលរដ្ឋ អំពីការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល។
- ជំរុញ និងគាំទ្រយន្តការច្រកចេញចូលតែមួយ ដើម្បីបង្វិតសេវាសាធារណៈឲ្យនៅកៀកជាមួយប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- បន្តគាំទ្រ និងជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពទាំង០៧ចំណុចសំដៅជានាសុខសន្តិភាព និងសុខដុមមេនានៅមូលដ្ឋាន។

### ❖ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់

- បន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បន្តខិតខំអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពទាំង ៧ចំនុចឱ្យបានល្អ
- បន្តអនុវត្តតាមផែនការអភិវឌ្ឍន៍ ០៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំ រំកិលរបស់រដ្ឋបាលឃុំ
- បន្តខិតខំប្រឹងប្រែងកៀងគរធនធាន ពីដៃគូដើម្បីអភិវឌ្ឍន៍នូវមូលដ្ឋាន ឱ្យកាន់តែរីកចម្រើនបន្ថែមទៀត

- បន្តអនុវត្ត និងពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង
- បន្តចាត់វិធានការអប់រំផ្សព្វផ្សាយបទបញ្ជារបស់រាជរដ្ឋាភិបាល និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។

## IV. សម្គាល់

នៅក្នុងសន្និសីទសារព័ត៌មាននេះ ទទួលបានសំណួរពីអ្នកសារព័ត៌មាន និងការពន្យល់បកស្រាយពីសំណាក់វាគ្មិនដូចខាងក្រោម៖

១. តើនៅក្នុងខេត្តកំពង់ចាម មានតំបន់ទេសចរណ៍ណាខ្លះ?

- នៅក្នុងខេត្តកំពង់ចាម វិស័យទេសចរណ៍ បានចូលរួមចំណែកយ៉ាងខ្លាំង ក្នុងការអភិវឌ្ឍ ជាពិសេសលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។ នៅក្នុងខេត្តទាំងមូល មានតំបន់ទេសចរណ៍សំខាន់ៗ ដែលទាក់ទាញទាំងភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដូចជា៖
    - ប្រសាទបុរាណជាច្រើនកន្លែង
    - ស្ពានឬស្សី និងឆ្នេរខ្សាច់កោះប៉ែន
    - រមណីយដ្ឋានភ្នំហាន់ជ័យ
    - រមណីយដ្ឋានទឹកធា និងសួនកម្សាន្តកុមារ។

៣. តើការធ្វើស្រែប្រាំង មានបញ្ហាប្រឈមដែរឬទេ? ហើយទទួលបានទិន្នផលប៉ុន្មាន?

- កសិករនៅក្នុងខេត្តកំពង់ចាមដែលធ្វើស្រែប្រាំង គឺពឹងផ្អែកលើប្រព័ន្ធធារាសាស្ត្រ។ ក្នុងឆ្នាំនេះ ប្រជាពលរដ្ឋបានធ្វើស្រែប្រាំងមុនរដូវ ដូចនេះ មិនមានបញ្ហាខ្វះទឹកឡើយ ហើយមន្ទីរកសិកម្មខេត្ត បានណែនាំឱ្យប្រជាពលរដ្ឋធ្វើស្រូវដែលមានអាយុកាលខ្លី និងសមស្របទៅនឹងប្រព័ន្ធទឹកដែលមាន។ ចំពោះទិន្នផលដែលទទួលបានជាមធ្យមគឺ ជាង៤តោន ទៅតាមតំបន់ខ្លះបានជាង៥តោន។

៤. តើមានឃុំណាខ្លះ ដែលពុំទាន់មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់?

- នៅក្នុងខេត្តកំពង់ចាមទាំងមូល មាន២ឃុំ ដែលមិនទាន់មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ គឺឃុំទួលសំបួរ និងឃុំអូរម្លូ ព្រោះជាឃុំដែលនៅដាច់ស្រយាល ប្រជាពលរដ្ឋមានទីលំនៅមិនប្រមូលផ្តុំគ្នា ពិបាកក្នុងការវិនិយោគ។ ក្នុងបញ្ហានេះ រដ្ឋបាលខេត្តបានកំពុងខិតខំជំរុញឱ្យក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណគ្រប់គ្រងទឹកស្អាត ពង្រីកបណ្តាញចែកចាយទឹកស្អាតនេះ ទៅដល់ឃុំទាំង២ខាងលើ ឱ្យស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលគឺនៅឆ្នាំ២០២៥ នឹងមានប្រព័ន្ធទឹកប្រើប្រាស់១០០%។

ថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២